# ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អនុញ្ញាតឱ្យសភាពាណិជ្ជកម្មម៉ាឡេស៊ី ប្រចាំកម្ពុជា ជួបពិភាក្សាការងារ

ថ្ងៃ ព្រហស្បតិ៍, 14 តុលា, 2021

នៅក្នុងជំនួបពិភាក្សាការងារ ជាមួយសភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំកម្ពុជា ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវិនិយោគិនម៉ាឡេស៊ី ដែលមានបំណងមកបណ្តាក់ទុនរកស៊ីនៅកម្ពុជា ស្របពេលដែលកម្ពុជា មានសុខសន្តិភាព ស្ថេរភាពនយោបាយ និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរួបវន្តទូទាំងប្រទេស ។

ជាកិច្ចឆ្លើយតប លោក Tan Khee Meng, ប្រធានសភាពាណិជ្ជកម្មម៉ាឡេស៊ីនៅកម្ពុជា និងជានាយកគ្រប់គ្រងនៃក្រុមហ៊ុនBaker Tilly (Cambodia) Co., Ltd.

បានបញ្ជាក់ថា អ្នកនិយោគទុនម៉ាឡេស៊ី នឹងគោរពច្បាប់វិនិយោគនៅកម្ពុជា ជាពិសេសនឹងប្រកាន់ខ្ជាប់នូវគោលការណ៍បរិស្ថាន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើររវាងប្រទេសទាំង២។ ជាមួយគ្នានេះដែរ វិនិយោគិនម៉ាឡេស៊ី កំពុងមានការចាប់អារម្មណ៍ខ្លាំង ការពង្រីកផែនការវិនិយោគនានា ទៅដល់ក្រុងព្រះសីហនុ ខេត្តព្រះសីហនុជាទីក្រុងថ្មី មានសក្តានុពលខ្ពស់ ការអភិវឌ្ឍលឿន និងជាទីក្រុងពហុបំណង។

គួរបញ្ជាក់ថា នៅក្នុងជំនួបពិភាក្សានេះ ក៏មានការអញ្ជើញចូលរួមពី លោក Terrance Teoh Yih Min, នាយកប្រតិបត្តិនៃធនាគារ Hong Leong Cambodia ,លោក Mohan Tirugmanasam Bandam, នាយកប្រតិបត្តិនៃកាសែត Khmer Times,លោក សេង ម៉េងតុង ប្រធាននាយកដ្ឋានផ្នែកច្បាប់នៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ផងដែរ។

ក្រសួងបរិស្ថាន
MINISTRY OF ENVIRONMENT

bakertilly













ក្រសួងបរិស្ថាន
MINISTRY OF ENVIRONMENT

bakertilly






Source: https://www.moe.gov.kh/index/34391